# ជីកំប៉ុស្តិ៍ទឹក

# និង

# ជីកំប៉ុស្តិ៍ទ្រុង

# ជីកំប៉ុស្តិ៍ទឹក

# ១-សារៈប្រយោជន៍

► ផ្តល់ជីជាតិដល់ដី

* បង្កើនផលិផលដំណាំតាមរយៈការប្រើប្រាស់សារធាតុសរីរាង្គ

* គឺមានគុណសម្បត្តិគ្រប់គ្រាន់ សំរាប់ជួយដល់កសិករយើង ពីព្រោះជីទឹកនេះ មានសារធាតុចិញ្ចឹមដែលរលាយ រួចជាស្រេច ងាយស្រួលដល់ដំណាំ

* ក្លិនរបស់ជីកំប៉ុស្តិ៍ទឹក អាចជួយដេញសត្វល្អិតមួយចំនួនដែល បំផ្លាញរុក្ខជាតិកុំឱ្យវាមកជិតដែរ ។

# ២-សំភារៈ និង វត្ថុធាតុដើមសំរាប់ជីកំប៉ុស្តិ៍ទឹក

## ក-សំភារៈ

- ពាងទឹកមួយ ឬ ធុងសាំង_ត្រូវមានគំរបក្រដាសរឹងគ្រប
- បាវធ្វើពីក្រចៅមួយ
- ដុំថ្មមួយដុំ សំរាប់សង្កត់ឱ្យបាវលិច



## ខ-វត្ថុធាតុដើមសំរាប់ធ្វើដីកំប៉ុស្តិ៍ទឹក

- លាមកសត្វ អាចម៍មាន់, ទា, ប្រចៀវ........ ។
- ស្លឹករុក្ខជាតិដែលមានឫសជ្រៅៗ ជាពិសេសរុក្ខជាតិ ដែលមានក្លិនខ្លាំង ដូចជា
  - ទន្ទ្រានខែត្រ, កន្ទ្រោបព្រៃ, ឬ ស្លឹកពពួករុក្ខជាតិដែលមានផ្លែជាកួរ ដូចជា
- - ស្លឹកអង្គារដី, កន្ទំថេត, អង្កាញ់ ........... ។

# ៣-របៀបធ្វើ

- ទន្រ្ទានខែត្រចំនួន ១០គ.ក្រ លាយអាចម៍ប្រចៀវ ៣ គ.ក្រនិងអាចម៍មាន់ ៣ គ.ក្រ
- បាវច្រកវត្ថុធាតុរួចជាស្រេច ដាក់ចូលទៅក្នុងពាង ដោយចំណុះទឹកស្មើរ ២០ ដង នៃចំណុះជី ។
- ត្រូវគ្របពាង ឬ ធុងសាំង ឱ្យបានល្អ ដើម្បីការពារកុំឱ្យ រុយមក ពងដាក់ និង ជះក្លិនស្អុយ ចេញមកក្រៅ ។

# ៤-ការកូរត្រឡប់ដីកំប៉ុស្តិ៍ទឹក

- ត្រូវកូរដីរៀងរាល់ថ្ងៃ ដោយមួយថ្ងៃ កូរពីរដង
- របៀបកូរគឺកូរបង្វិលទៅ បង្វិលមក ឱ្យបានប្រហែល ៥ នាទី
- ការកូរដីបានទៀងទាត់ គឺមានសារៈសំខាន់ណាស់ ពីព្រោះវានាំខ្យល់ (អុកស៊ីសែន) ចូលក្នុងទឹក ហើយបង្ក លក្ខខណ្ឌ ឱ្យពួកសត្វល្អិតតូចៗ មានសកម្មភាពខ្លាំង ។
- បើយើងមិនកូរ នោះដីរបស់យើង នឹងសំបូរទៅដោយពពួកមេរោគ

# ៥-ការសំរេចបានជីកំប៉ុស្តិ៍ទឹក

- ក្នុងរយៈពេល ៣ អាទិត្យ គឺនៅពេលលែងមានក្លិនស្អុយ ។
- អាចរក្សាទុកក្នុងរយៈពេល ១ ខែទៀត តែត្រូវទុកវាក្រោមម្លប់ ។ នៅពេលជាមួយគ្នានោះ យើងត្រូវជៀសវាង បោះវត្ថុធាតុដើមចូលបន្ថែមទៀត គឺប្រើឱ្យអស់សិន រួចចាំធ្វើថ្មីតែម្តង

# ៦-ការប្រើប្រាស់ជីកំប៉ុស្តិ៍ទឹក

**ក-ដំណាក់កាលសំខាន់ៗសំរាប់ប្រើប្រាស់ជីកំប៉ុស្តិ៍ទឹក ៖**

- ១សប្តាហ៍ក្រោយស្ទូង នៅពេលកូនដំណាំកំពុងលូតលាស់ ឬ ដាំកូន
- នៅមុនពេលដំណាំចេញផ្កា
- នៅពេលដំណាំជួបរោគសញ្ញាប្លែកៗ (ស្លឹកមានការប្តូរពណ៌, ឬ បង្ហាញនូវរោគខ្វះជីជាតិ )

## ខ-របៀបស្រោច

- គេស្រោចទឹក ១ លីត្រ លើផ្ទៃដី ១ ម៉ែក្រឡា ឬ ១០០ លីត្រ សំរាប់ផ្ទៃដី ១០០ ម៉ែត្រក្រឡា ។
- តែបើស្រោចលើស្លឹកដំណាំផ្កាល់ គេត្រូវលាយជីជាមួយទឹកធម្មតា
- មួួយទល់មួយ ។



- យើងគួរស្រោច ១ សប្ដាហ៍ម្ដង តែបើដំណាំខ្វះ ជីជាតិខ្លាំង យើងអាចស្រោចពី ២ ទៅ ៣ ដង ក្នុង ១ សប្ដាហ៍ ។

## សេចក្ដីបញ្ជាក់

ប្រសិនបើយើងត្រូវការប្រើជីកំប៉ុស្ដិ៍ទឹកច្រើន ឬ ប្រើជាបន្ដជាប់ៗ គ្នានោះ យើងត្រូវតែធ្វើជីនេះ យ៉ាងតិចចាប់ពី ២ ទៅ ៣ ពាងឡើងទៅ ។

# របៀបធ្វើជីកំប៉ុស្ដិ៍ក្រូច

## របៀបធ្វើទ្រុងកំប៉ុស្តិ៍

គេអាចធ្វើទ្រុងកំប៉ុស្តិ៍បាន ២ ប្រភេទដែលមានទំហំផ្សេងៗពីគ្នា

ទ្រុងកំប៉ុស្តិ៍ប្រភេទទី ១ ( ទ្រុងតូច ១ម X ១ម X ១ម )

ទ្រុងកំប៉ុស្តិ៍ប្រភេទទី ២ ( ទ្រុងធំ ២ម X ១,៥ម X ១ម )

## ក-សំភារ

បន្ទះរនាបឬស្សី ឬ ឈើទំហំ ៣ ស.ម ទៅ ៤ ស.ម ។ដែកគោលកាំបិត ចប ពូថៅ ញញួរ រណារ ។

## ខ-របៀបធ្វើ

កាត់បន្ទះរនាបឬស្សី ឬ ឈើគឺអាស្រ័យទៅតាមប្រភេទទ្រុងដែលយើងកំណត់ ។

- វាយបន្ទះរនាបឫស្សី ឬ ឈើ ដោយទុកគំលាតបន្ទះ មួយទៅ បន្ទះមួយទៀត ប្រមាណ ២ ស.ម ។
- ធ្វើរបៀបនេះឱ្យបាន ៤ ផ្ទាំង ដើម្បីផ្គុំគ្នាឱ្យបានជាទ្រុងកំប៉ុស្តិ៍

## ទីតាំងទ្រុងកំប៉ុស្តិ៍

- ទ្រុងកំប៉ុស្តិ៍ត្រូវស្ថិតនៅក្រោមម្លប់ (កុំឱ្យត្រូវកំដៅថ្ងៃ) ក្បែរប្រភពទឹក ឬ ក្បែរទ្រុងជ្រូក ។

# ការតំឡើងទ្រុងកំប៉ុស្តិ៍

- ត្រូវកាប់បំផុសដី បាតទ្រុងកំប៉ុស្តិ៍ ដើម្បីឱ្យមានខ្យល់ចេញចូល
- ត្រូវដាក់បង្គោលមូលមួយទំហំ ពី ៨ ស.ម - ១០ ស.ម ចំកណ្តាលសំរាប់កំប៉ុស្តិ៍ទ្រុងតូច ។
- ត្រូវដាក់បង្គោលចំនួន ៣ សំរាប់កំប៉ុស្តិ៍ទ្រុងធំ
- ផ្គុំផ្ទាំងទ្រុងទាំង ៤ ដោយចងខ្សែ



# វត្ថុធាតុដើមដែលយកមកផ្សំ

- លាមកសត្វដូចជា: អាចម៍គោ, មាន់, ទា, ជ្រូក.......។
- វត្ថុធាតុស្រស់ដូចជា: ស្មៅ, ដើមចេក, កាកសំណល់បន្លែ, ទន្រ្ទានខែត្រ..
- វត្ថុធាតុស្ងួតដូចជា: ស្មៅក្រៀម, ចំបើង, សំបកពោត........។

# ការរៀបចំវត្ថុធាតុដើម

- រៀបវត្ថុស្ងួតដែលចិញ្ច្រាំហើយ កំរាស់ ២៥ ស.ម ដោយស្រោចទឹកជាន់បង្ហាប់ឱ្យជោគ
- រៀបវត្ថុធាតុស្រស់ដែលចិញ្ច្រាំហើយ កំរាស់ ១0 ស.ម -១៥ ស.ម  ដោយចាក់ ទឹកផ្សើមតិចៗ ។
- ដាក់លាមកសត្វកំរាស់ ៥ ស.ម



- អាចដាក់ផេះ ពីលើលាកមសត្វកំរាស់ 0,៥ ស.ម- ១ ស.ម
- ធ្វើរបៀបនេះរហូតដល់ពេញទ្រុង
- បន្ទាប់ពីរៀបវត្ថុធាតុដើមពេញទ្រុងហើយដកបង្គោលចេញដើម្បីឱ្យមានរន្ធខ្យល់
- ត្រូវបន្តការស្រោចទឹក ឬ ទឹកនោមជ្រូកឱ្យបានគ្រប់គ្រាន់ ។
- ការធ្វើជីកំប៉ុស្តិ៍នៅរដូវវស្សាឆាប់រលួយជាង រដូវប្រាំង ។

# រយៈពេលទទួលបានជីកំប៉ុស្តិ៍

- ជីកំប៉ុស្តិ៍ទ្រុងតូច ជាធម្មតា ៤៥ - ៥០ ថ្ងៃ ក្រោយ ការរៀបចំរួច ។ប៉ុន្តែត្រូវជ្រោយត្រឡប់ ៧ -១០ ថ្ងៃម្តង
- ជីកំប៉ុស្តិ៍ទ្រុងធំរយៈពេលពី ២ - ៣ ខែ និងប្រើប្រាស់បាន ។
- ការធ្វើកំប៉ុស្តិ៍ទ្រុងធំនេះមិនចាំបាច់ជ្រោយត្រឡប់ទេ តែទាមទារឱ្យធ្វើការស្រោចទឹក ឬ ទឹកនោមជ្រូកជាប្រចាំ (ក្នុងរយៈពេល ៥ - ៧ ថ្ងៃម្តង។

**គេសំគាល់ដីកំប៉ុស្តិ៍អាចប្រើបានដូចខាងក្រោមៈ**

*សំបុរពណ៌ត្នោតក្រម៉ៅ

* កំដៅថយចុះជាធម្មតា

* មិនមានក្លិន

* មានសត្វដូចជា ជន្លេន, ដង្កូវខ្យង រស់នៅក្នុងនោះ

* មានគ្រាប់រុក្ខជាតិ អាចដុះចេញពីកំប៉ុស្តិ៍បាន

# ការប្រើប្រាស់ជីកំប៉ុស្តិ៍

ប្រើលាយជាមួយដី សំរាប់សាប និង ផ្សាំកូនបន្លែ ក្នុងកន្ទោង

ប្រើជាប្រភេទជីទ្រាប់បាត ៣00 គ.ក្រ លើផ្ទៃដី ១00 ម២

- នៅពេលប្រើត្រូវច្របល់ ឬ រាស់លុបឱ្យសព្វចូលក្នុងដី ដើម្បីជៀសវាងការហើរជី អាសូត ដែល មាននៅក្នុងជីកំប៉ុស្តិ៍ ។



ជីកំប៉ុស្តិ៍

គេអាចច្រកបាវរក្សាទុកដើម្បីប្រើប្រាស់ពេលក្រោយបាន

